វគ្គសិក្សាសាលាអំពី :

# មូលដ្ឋានគ្រឹះនៃគណនេយ្យភាពសង្គម

## Fundaments of Social Accountability



សំរបសំរួលដោយ :

អង្គការសីលការ

# គោលដៅនៃវគ្គសិក្ខាសាលា

ដើម្បីពង្រឹងចំណេះដឹង និងសមត្ថភាពស្តីពី ***"គណនេយ្យភាពសង្គម"*** ដល់សិក្ខាកាម ជាមន្ត្រីមកពីអង្គភាព ថ្នាក់ជាតិ រដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល ថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ ដែលជាដៃគូអនុវត្តគម្រោងអភិបាលកិច្ចល្អមូលដ្ឋាន។ វគ្គសិក្ខាសាលា នេះនឹងផ្តល់នូវ ទស្សនាទាន ដំណើរការ និងឧបករណ៍នានា នៃគណនេយ្យភាពសង្គម ដល់សិក្ខាកាម ដើម្បីឱ្យពួកគាត់អាចយកចំណេះទៅ ចែករំលែកបន្តដល់មន្ត្រីនិងបុគ្គលិក ដទៃទៀតក្នុងអង្គភាពរបស់គាត់ សម្រាប់ រួមចំណែកដល់ ការធ្វើឱ្យប្រសើរឡើងនូវ អភិបាលកិច្ច សំដៅធ្វើឱ្យប្រជាពលរដ្ឋទទួលបានសេវាសាធារណៈកាន់តែល្អប្រសើរ។

# ទិសដៅនៃវគ្គសិក្ខាសាលា

បន្ទាប់ពីវគ្គសិក្ខាសាលានេះ សិក្ខាកាមនឹងអាចៈ

១. កំណត់បាននូវការប្រឈមចំពោះអភិបាលកិច្ច និងទស្សនរបស់គាត់ចំពោះប្រទេស កម្ពុជា

២. យល់ដឹងកាន់តែប្រសើរពី ទស្សនាទាននៃ គណនេយ្យភាព និង គណនេយ្យភាពសង្គម

៣. ភ្ជាប់ទំនាក់ទំនងរវាង គណនេយ្យភាពសង្គម អភិបាលកិច្ចល្អ វិមជ្ឈការ ដែលឆ្ពោះទៅរកសង្គមល្អ

៤. កំណត់បាននូវតួនាទីនៃតួអង្គនៃអភិបាលកិច្ចល្អ

៥. យល់ដឹងពីការកៀរគរការចូលរួមរបស់ពលរដ្ឋក្នុងការអនុវត្តគណនេយ្យភាពសង្គម

៦. យល់ដឹងពីឧបករណ៍គណនេយ្យភាពសង្គមនានា។

# រចនាសម្ព័ន្ធមេរៀន




- ការយល់ដឹងពីសង្គមស៊ីវិល
- ការពង្រឹងការចូលរួមរបស់ពលរដ្ឋ
- ទស្សនៈយេនឌ័រលើអភិបាលកិច្ចល្អ
- ភាពជាពលរដ្ឋ

# របៀបសិក្សា



សកម្មភាព
ចែករំលែកបទពិសោធន៍
ការគិត
ចូលរួមសកម្មភាពផ្សេងៗ
សិក្សា
ឆ្លុះបញ្ចាំង
សិក្សាទ្រឹស្តី និង
ស្ថានភាពនៅកម្ពុជា
វិធីសាស្រ្ត
ចូលរួម
ការកែតម្រូវ
ពិភាក្សាពីការបង្កើន
ឡើងវិញ

# ការសង្ខេបមេរៀន របស់ក្រុម

១. តើចំណុចសំខាន់អ្វីខ្លះនៃមេរៀន ដែលអ្នកបានរៀនពីម្សិលមិញ?

២. តើអ្វីដែលថ្មីសម្រាប់អ្នក?

៣. តើអ្វីដែលទាក់ទងនឹងការងាររបស់អ្នក?

# សំណួរ ?

# សង្គមល្អ

១. តើសង្គមល្អ មានន័យដូចម្តេច សម្រាប់អ្នក?

២. តើគួរធ្វើអ្វីខ្លះ ដើម្បីទទួលបានសង្គមល្អ?

៣. តើអ្នកណា គួរធ្វើអ្វីខ្លះ?

# អភិបាលកិច្ច

១. តាមការយល់របស់អ្នក តើអភិបាលកិច្ចគឺជាអ្វី?

២. តើគោលនយោបាយជាតិអ្វីខ្លះ ដែលគាំទ្រដល់អភិបាលកិច្ចនៅកម្ពុជា?

៣. តើយុទ្ធសាស្ត្រ /កម្មវិធីជាតិអ្វីខ្លះដែលបានដាក់ចេញដើម្បីអនុវត្តអភិបាលកិច្ច?

តើអ្វីជាស្នូល នៃយុទ្ធសាស្ត្រចតុកោណ

របស់រាជរដ្ឋាភិបាលកម្ពុជា?

ហេតុអ្វី?



## យុទ្ធសាស្ត្រចតុកោណ
## នៃរាជរដ្ឋាភិបាលកម្ពុជា

### ① ការលើកស្ទួយវិស័យកសិកម្ម

- ការលើកកម្ពស់ផលិតភាព និងពិពិធកម្មវិស័យកសិកម្ម
- កំណែទម្រង់ដីធ្លី និងបោសសំអាតមីន
- កំណែទម្រង់វិស័យ នេសាទនិងជលផល
- កំណែទម្រង់ព្រៃឈើ

### ② ការបន្តស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

- ការធនធានទឹកនិងប្រពន្ធ័ ធារាសាស្ត្រ
- ការអភិវឌ្ឍបច្ចេកវិទ្យា ព័ត៌មាន និងទូរគមនាគមន៍
- ការបន្តស្តារនិងកសាងហេដ្ឋា រចនាសម្ព័ន្ធទូរគមនាគមន៍
- ការអភិវឌ្ឍវិស័យថាមពល និងបណ្តាញអគ្គិសនី

### ③ កសាងសមត្ថភាព និងអភិវឌ្ឍធនធានមនុស្ស

- ការពង្រឹងគុណភាព វិស័យអប់រំ
- ការលើកកម្ពស់ សេវាសុខាភិបាល
- ការអនុវត្តគោលនយោបាយ សមភាពផ្នែកភេទ
- ការអនុវត្តគោលនយោបាយ ប្រជាជន

### ④ ការអភិវឌ្ឍផ្នែកឯកជន និងការងារ

- ការបង្កើតការងារ និងការធានាលក្ខណ្ឌការងារល្អ
- ការរៀបចំប្រពន្ធ័សុវត្ថិភាព សង្គម
- ការពង្រឹងវិស័យឯកជន និង ការទាក់ទាញវិនិយោគ
- ការលើកស្ទួយសហគ្រាសធុនតូចនិងមធ្យម

### បរិបទ

- **ស្ថេរភាព សុខសន្តិភាព និងសណ្តាប់ធ្នាប់សង្គម**
- **សមាហរណកម្មកម្ពុជា នៅក្នុងតំបន់និងពិភពលោក**
- **ភាពជាដៃគូ ក្នុងការអភិវឌ្ឍ**
- **បរិស្ថានម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមានលក្ខណៈអនុគ្រោះ**

### អភិបាលកិច្ចល្អ

| | |
|---|---|
| ប្រយុទ្ធប្រឆាំងនឹង អំពើពុករលួយ | កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ |
| កំណែទម្រង់រដ្ឋបាល សាធារណៈ | កំណែទម្រង់កង កម្លាំងប្រដាប់អាវុធ |

# អភិបាលកិច្ចល្អ

តើអភិបាលកិច្ចល្អ ជាតួនាទីរបស់អ្នកណា?

ហេតុអ្វី?



# គណនេយ្យភាព

១. បើមានពាក្យអ្វីខ្លះដែលទាក់ទងនឹង "គណនេយ្យភាព"?

២. តើមានយន្តការអ្វីខ្លះ ដែលអនុវត្តក្នុងការលើកកម្ពស់ "គណនេយ្យភាព"របស់មន្ត្រីសាធារណៈ?

យន្តការនយោបាយ? យន្តការសារពើពន្ធ? យន្តការរដ្ឋបាល?

យន្តការច្បាប់?

# គណនេយ្យភាព សង្គម

១. បើតាមការយល់របស់អ្នក តើអ្វីជា"គណនេយ្យភាពសង្គម"?

២. ហេតុអ្វី បានជាគណនេយ្យភាពសង្គមសំខាន់?

៣. បច្ចុប្បន្ននេះ តើមានយន្តការ ឬសកម្មភាពគណនេយ្យភាពសង្គម អ្វីខ្លះកំពុងអនុវត្តនៅកម្ពុជា?

# វិមជ្ឈការ

១. បើតាមការយល់របស់អ្នក តើវិមជ្ឈការគឺជាអ្វី?

២. តើក្របខណ្ឌច្បាប់អ្វីដែលគាំទ្រដល់វិមជ្ឈការនៅកម្ពុជា?

៣. តើយន្តការ និងសកម្មភាពវិមជ្ឈការអ្វីខ្លះ ដែលអនុវត្តនៅកម្ពុជា?

សំណួរបន្ទាប់ទៀត តម្រូវឱ្យអ្នកលើកកាតបញ្ជាក់ចម្លើយ

- ពណ៌ទឹកក្រូច = មិនទាក់ទង
- ពណ៌ខៀវ = ទាក់ទង

# សំណួរ

១. សង្គមស៊ីវិល

២. រដ្ឋាភិបាល

៣. អ្នកមានសិទ្ធិអំណាច

៤. អ្នកធ្វើអភិបាលកិច្ច

៥. ពលរដ្ឋ

៦. អ្នកលើកកម្ពស់ឃែនឌ័រ

៧. អ្នកពង្រឹងភាពអង់អាច

# ចំណុចសំខាន់នៃមេរៀន "អភិបាលកិច្ចល្អ"

## សង្គមល្អ

- សង្គមល្អគឺជាលទ្ធផលចុងក្រោយនៃអភិបាលកិច្ចល្អ ដែលរួមមានការបំពេញបានតម្រូវការរស់នៅជាមូលដ្ឋាន ការរួបរួមសាមគ្គី និងការបង្កឱ្យមានការចូលរួម។
- ពលរដ្ឋ និងរដ្ឋ មានតួនាទីធ្វើឱ្យកើតមានសង្គមល្អ។

## អភិបាលកិច្ចល្អ

- អភិបាលកិច្ចល្អ ជាដំណើរការគ្រប់គ្រងដោយការមានចូលរួមពី រដ្ឋាភិបាល វិស័យឯកជន និងសង្គមស៊ីវិល ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការពិតប្រាកដរបស់ប្រជាពលរដ្ឋ
- អភិបាលកិច្ចល្អកើតមាន ទាល់តែមានឆន្ទៈនយោបាយ ក្របខណ្ឌច្បាប់ ការអនុវត្តលទ្ធិប្រជាធិបតេយ្យ
- អភិបាលកិច្ចជាបេះដូង នៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា
- ចង់បានអភិបាលកិច្ចល្អទាល់តែមាន ការចូលរួម គណនេយ្យភាព តម្លាភាព។

# ចំណុចសំខាន់នៃមេរៀន "គណនេយ្យភាពសង្គម"

- គណនេយ្យភាពសង្គម ជាវិធីដែលប្រជាពលរដ្ឋអនុវត្តដើម្បី :
  - ពង្រឹងអភិបាលកិច្ចល្អ
  - ប្រសិទ្ធភាពនៃការអភិវឌ្ឍ
  - ពង្រឹងភាពអង់អាច។

- លទ្ធិប្រជាធិបតេយ្យមិនអាចកើតមាន ដោយគ្មានវិមជ្ឈការ
- វិមជ្ឈការបែបប្រជាធិតេយ្យ គឺធ្វើឱ្យការសម្រេចចិត្តស្ថិតនៅកៀកនឹងប្រជាពលរដ្ឋ។
- ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការសម្រេចចិត្ត នាំឱ្យការអភិវឌ្ឍន៍ប្រកបដោយនិរន្តភាព។

# ចំណុចសំខាន់នៃមេរៀន "ការចូលរួមរបស់ពលរដ្ឋ"

- អភិបាលកិច្ចល្អមិនអាចកាត់ផ្តាច់ចេញនូវការចូលរួមពីគ្រប់ភាគី
- ការចូលរួមរបស់ពលរដ្ឋ គឺផ្អែកលើមូលដ្ឋាន "ភាពជាពលរដ្ឋ"
- សិទ្ធិ និងកាតព្វកិច្ច គឺជាស្នូលនៃភាពជាពលរដ្ឋ
- តួនាទីរបស់រដ្ឋគឺការពារប្រជាពលរដ្ឋ ក្នុងការប្រើប្រាស់សិទ្ធិដើម្បីចូលរួម។

# ចំណុចសំខាន់នៃមេរៀន "ឧបករណ៍គណនេយ្យភាពសង្គម"

នៅក្នុងរដ្ឋប្រជាធិបតេយ្យ ប្រជាពលរដ្ឋប្រើឧបករណ៍គណនេយ្យភាពសង្គម

នៅគ្រប់ដំណាក់កាលនៃអភិបាលកិច្ច ចាប់តាំងពីដំណើរការបោះឆ្នោត

ការបង្កើតគោលនយោបាយ ការធ្វើផែនការនិងចាត់ចែងធនធាន

ការប្រើប្រាស់ធនធាន និងការផ្តល់សេវា

ដើម្បី

ពង្រឹងអភិបាលកិច្ចល្អ និងប្រសិទ្ធភាពនៃការអភិវឌ្ឍ។

# សូមអរគុណ

## ចំពោះការយកចិត្តទុកដាក់តាមដានស្តាប់របស់លោកអ្នក

